ក្រមប្រតិបត្តិ
និងក្រមសីលធម៌ក្នុងការប្រកបអាជីវកម្ម

គោលការណ៍ទូទៅ

ក្រុមហ៊ុន Crown Holdings, Inc. និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនមានគោលការណ៍ថានាយក មន្ត្រី និងនិយោជិតគ្រប់រូបត្រូវគោរព និងប្រតិបត្តិតាមរាល់លិខិតបទដ្ឋាន និងស្មារតីនៃច្បាប់ វិធាន និងបទប្បញ្ញត្តិជាធរមាននានាគ្រប់ពេលវេលា និងគ្រប់មធ្យោបាយទាំងអស់ ហើយនិយោជិតគ្រប់រូបត្រូវព្យាយាមប្រកាន់ខ្ជាប់នូវស្តង់ដារខ្ពស់បំផុតនៃក្រមសីលធម៌ សីលធម៌ ភាពស្មោះត្រង់ និងភាពល្អប្រសើរក្នុងការបំពេញភារកិច្ចរបស់ខ្លួន។ ក្រុមហ៊ុន Crown ក៏រំពឹងថាគ្រប់ភាគីទីបីដែលក្រុមហ៊ុន Crown មានទំនាក់ទំនងពាណិជ្ជកម្មជាមួយយ៉ាងសកម្មសម្រាប់ការផ្គត់ផ្គង់ទំនិញ ឬសេវាកម្ម ដែលរួមមានអ្នកផ្គត់ផ្គង់វត្ថុធាតុដើម និងគ្រឿងម៉ាស៊ីន អ្នកផ្គត់ផ្គង់ទំនិញ និងសេវាកម្មផ្សេងទៀត អ្នកម៉ៅការ អ្នកប្រឹក្សា ឈ្មួញកណ្តាល និងភ្នាក់ងារត្រូវគោរពតាមគោលការណ៍នៅក្នុងក្រមនេះក្នុងលក្ខណៈដែលមានចែងក្នុងក្រមប្រតិបត្តិស្តីពីការផ្គត់ផ្គង់របស់ក្រុមហ៊ុន។

គោលការណ៍ជាក់លាក់

ដើម្បីជានាថា និយោជិតគ្រប់រូបប្រកាន់ខ្ជាប់នូវគោលការណ៍ទូទៅ ក្រុមហ៊ុន Crown បានអនុម័តគោលការណ៍ជាក់លាក់មួយចំនួនដែលមានចែងនៅខាងក្រោម។ ទោះបីជាគោលការណ៍ជាក់លាក់ទាំងនោះមិនគ្របដណ្តប់គ្រប់ស្ថានភាពដែលអាចគិតដល់បានដែលនិយោជិតអាចប្រឈមមុខក៏ដោយ ក៏គោលការណ៍ជាក់លាក់ទាំងនោះដោះស្រាយបញ្ហាមួយចំនួនដែលអាចកើតឡើង។ ប្រសិនបើនិយោជិតណាម្នាក់មានសំណួរណាមួយអំពីថាតើការប្រព្រឹត្តមួយចំនួនមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ឬត្រូវនឹងបទដ្ឋានរបស់ក្រុមហ៊ុន Crown ឬទេ និយោជិតនោះគួរតែសាកសួរប្រធានផ្ទាល់របស់ខ្លួន អ្នកគ្រប់គ្រងរោងចក្រ ឬនាយកដ្ឋានច្បាប់នៅក្នុងផ្នែករបស់ខ្លួនភ្លាមៗ។ ប្រសិនបើមិនមានការកត់សម្គាល់ផ្សេងពីនេះ គោលការណ៍ជាក់លាក់ និងឯកសារយោងទាក់ទងនឹងក្រុមហ៊ុន Crown ឬ “និយោជិក” របស់ក្រុមហ៊ុន អនុវត្តចំពោះនិយោជិក មន្ត្រី និងនាយកគ្រប់រូបរបស់ក្រុមហ៊ុន Crown Holdings, Inc. និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន។ ក្រុមហ៊ុន Crown នឹងអនុវត្តគោលការណ៍ជាក់លាក់ក្នុងលក្ខណៈស្របតាមច្បាប់ វិធាន និងបទប្បញ្ញត្តិដែលមានជាធរមាននៅក្នុងយុត្តាធិការដែលក្រុមហ៊ុន Crown Holdings, Inc. និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនប្រកបអាជីវកម្ម។

គោលការណ៍ស្តីពីទំនាស់ផលប្រយោជន៍ និងឱកាសសាជីវកម្ម

ក្រុមហ៊ុន Crown មានគោលការណ៍ហាមឃាត់មិនឱ្យមានទំនាស់ផលប្រយោជន៍ លើកលែងតែមានការយល់ព្រមពីក្រុមប្រឹក្សាភិបាល។ “ទំនាស់ផលប្រយោជន៍” កើតឡើងនៅពេលដែលផលប្រយោជន៍ឯកជនរបស់បុគ្គលប៉ះពាល់ដល់ផលប្រយោជន៍របស់ក្រុមហ៊ុន Crown។ ស្ថានភាពនៃទំនាស់អាចកើតឡើងនៅពេលដែលនិយោជិត មន្ត្រី ឬនាយកចាត់វិធានការ ឬមានផលប្រយោជន៍ដែលអាចធ្វើឱ្យមានការលំបាកក្នុងការបំពេញការងាររបស់ខ្លួនដោយមិនលម្អៀង និងមានប្រសិទ្ធភាពឱ្យក្រុមហ៊ុន Crown។ ឧទាហរណ៍ ប្រសិនបើគាត់មានតួនាទីនៅក្នុងស្ថាប័នមួយដែលធ្វើអាជីវកម្ម ឬប្រកួតប្រជែងនឹងក្រុមហ៊ុន Crown។ ទំនាស់ផលប្រយោជន៍ក៏កើតមានផងដែរនៅពេលនិយោជិត មន្ត្រី ឬនាយក ឬ សមាជិកគ្រួសាររបស់គាត់ទទួលបានផលប្រយោជន៍ផ្ទាល់ខ្លួនមិនត្រឹមត្រូវដោយសារតែតំណែងរបស់គាត់នៅក្នុងក្រុមហ៊ុន។ រាល់និយោជិត មន្ត្រី ឬនាយករបស់ក្រុមហ៊ុន Crown ដែលមានសំណួរទាក់ទងនឹងទំនាស់ផលប្រយោជន៍ដ៏ធំគួរតែពិគ្រោះយោបល់ជាមួយនាយកដ្ឋានច្បាប់នៅក្នុងផ្នែករបស់ខ្លួន។

បានធ្វើបច្ចុប្បន្នភាពថ្ងៃទី 23 ខែកក្កដា ឆ្នាំ 2026

<u>ឱកាសសាជីវកម្ម</u>

និយោជិតរបស់ក្រុមហ៊ុន Crown មានការកិច្ចដំរុញផលប្រយោជន៍ស្របច្បាប់របស់ក្រុមហ៊ុន Crown នៅពេលដែលឱកាសនេះមកដល់ និងត្រូវបានហាមឃាត់មិនឱ្យ៖

- ឆ្លៀតយកឱកាសផ្ទាល់ខ្លួនដែលរកឃើញតាមរយៈការប្រើប្រាស់ទ្រព្យសម្បត្តិ ព័ត៌មាន ឬមុខតំណែងរបស់សាជីវកម្ម
- ប្រើប្រាស់ទ្រព្យសម្បត្តិ ព័ត៌មាន ឬមុខតំណែងរបស់សាជីវកម្មដើម្បីផលចំណេញផ្ទាល់ខ្លួន និង
- ប្រកួតប្រជែងជាមួយក្រុមហ៊ុន Crown។

<u>ការការពារ និងការប្រើទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន</u>

និយោជិតរបស់ក្រុមហ៊ុន Crown គួរតែប្រឹងប្រែងការពារទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន និងធានាឱ្យមានការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព។ ការលួច ការធ្វេសប្រហែស និងការខ្ជះខ្ជាយមានផលប៉ះពាល់ផ្ទាល់លើលទ្ធភាពរកប្រាក់ចំណេញរបស់ក្រុមហ៊ុន។ ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន Crown រួមមានកុំព្យូទ័រ និងប្រព័ន្ធទំនាក់ទំនង និងព័ត៌មានអេឡិចត្រូនិក និងឯកសារនានា គឺត្រូវបានប្រើប្រាស់សម្រាប់តែគោលបំណងអាជីវកម្មសមស្រប និងសម្រាប់ការប្រើប្រាស់ ការចូលប្រើប្រាស់ និងសកម្មភាពនានាដែលអនុញ្ញាតដោយអ្នកគ្រប់គ្រងរបស់និយោជិតប៉ុណ្ណោះ។

គោលការណ៍ជួញដូរមូលបត្រ

ការជួញដូរភាគហ៊ុន ឬមូលបត្រផ្សេងទៀតរបស់ក្រុមហ៊ុនជួញដូរជាសាធារណៈ ឬ “ការផ្តល់ព័ត៌មាន” ដល់អ្នកដទៃអំពីឯកសារ ព័ត៌មានអសាធារណៈ ត្រូវបានហាមឃាត់តាមច្បាប់របស់សហរដ្ឋអាមេរិក ហើយជាទូទៅត្រូវបានហាមឃាត់នៅក្នុងប្រទេសដទៃទៀត ហើយគួរតែខិតខំជៀសវាងនូវរូបភាពណាមួយដែលនិយោជិតណាម្នាក់របស់ក្រុមហ៊ុន Crown ធ្វើការទិញ ឬលក់ភាគហ៊ុន ឬមូលបត្រផ្សេងទៀតរបស់ក្រុមហ៊ុន Crown (ដូចជាមូលបត្រ អតិថិជន ឬអ្នកផ្គត់ផ្គង់របស់ក្រុមហ៊ុន Crown) បានធ្វើតាមរបៀបមួយដើម្បីរកប្រាក់ចំណេញពីព័ត៌មានពីផ្ទៃក្នុងបែបនេះ។ និយោជិតរបស់ក្រុមហ៊ុន Crown មិនត្រូវបានអនុញ្ញាតឱ្យប្រើ ឬចែករំលែកឯកសារ ព័ត៌មានអសាធារណៈសម្រាប់គោលបំណងជួញដូរភាគហ៊ុនឡើយ។ ច្បាប់របស់សហរដ្ឋអាមេរិកដែលត្រូវបានអនុវត្តសម្រាប់ការជួញដូររបស់អ្នកផ្ទៃក្នុងអនុវត្តមិនត្រឹមតែចំពោះភាគហ៊ុនរបស់ក្រុមហ៊ុន Crown ដែលកាន់កាប់ផ្ទាល់ដោយនិយោជិតរបស់ក្រុមហ៊ុន Crown និងគ្រួសារជិតស្និទ្ធរបស់ពួកគេផ្ទាល់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងភាគហ៊ុនរបស់ក្រុមហ៊ុន Crown ដែលជាអត្ថប្រយោជន៍របស់និយោជិតណាម្នាក់ ឬគណនីចូលនិវត្តន៍ដែលនិយោជិតមានសិទ្ធិ ឬសមត្ថភាពធ្វើការណែនាំពីការវិនិយោគរបស់ពួកគេផងដែរ។

ព័ត៌មានផ្ទៃក្នុងមិនងាយកំណត់ទេ ប៉ុន្តែជាទូទៅ មានន័យថា ព័ត៌មានអសាធារណៈដែលអ្នកវិនិយោគសមស្របនឹងពិចារណាធ្វើការសម្រេចចិត្តពីការទិញ កាន់កាប់ ឬលក់ភាគហ៊ុននៅក្នុងក្រុមហ៊ុនជួញដូរជាសាធារណៈ។ ដោយសារតែបទដ្ឋាននេះអាចមានភាពមិនសុក្រឹត បញ្ហាអាចកើតមាននៅផ្នែកម្ខាងដែលមិនធ្វើការជួញដូរដើម្បីធ្វើឱ្យប្រាកដថាមិនមានសូម្បីតែរូបភាពនៃការប្រព្រឹត្តមិនត្រឹមត្រូវ។

ក្រុមហ៊ុន Crown លើកទឹកចិត្តឱ្យនិយោជិតរបស់ខ្លួនវិនិយោគលើភាគហ៊ុនរបស់ក្រុមហ៊ុន Crown សម្រាប់រយៈពេលវែង។ ការជួញដូររយៈពេលខ្លីដោយនិយោជិតរបស់ក្រុមហ៊ុន Crown ជាពិសេស អាចមានលេចជារូបភាពនៃការជួញដូររបស់អ្នកខាងក្នុង។ ដូច្នេះ វាជាគោលការណ៍របស់ក្រុមហ៊ុន Crown ក្នុងការមិនលើកទឹកចិត្តទាល់តែសោះនូវការជួញដូររយៈពេលខ្លីនូវភាគហ៊ុនរបស់ក្រុមហ៊ុន Crown។

ដើម្បីរក្សាបាននូវការប្រតិបត្តិតាមគោលការណ៍ការជួញដូរមូលបត្ររបស់ក្រុមហ៊ុន Crown ក្រុមហ៊ុន Crown តម្រូវឱ្យនិយោជិតដែលជាទូទៅអាចចូលប្រើប្រាស់នូវឯកសារ ព័ត៌មានអសាធារណៈ ទោះបីជាបុគ្គលនោះមិនអាចចូលប្រើប្រាស់នូវព័ត៌មានបែបនេះនៅពេលទិញ ឬលក់ក៏ដោយ ត្រូវ

ទទួលបានការអនុម័តសម្រាប់ការជួញដូរណាមួយពីនាយកដ្ឋានច្បាប់ជាមុនអំពីការជួញដូរជាក់ស្តែង។ រាល់និយោជិតរបស់ក្រុមហ៊ុន Crown ដែលមានសំណួរអំពីការប្រព្រឹត្តត្រឹមត្រូវរបស់ខ្លួនតាមគោលការណ៍នេះគួរតែស្វែងរកដំបូន្មានពីនាយកដ្ឋានច្បាប់របស់ក្រុមហ៊ុន Crown។

ដោយសារក្រុមហ៊ុន Crown ជាអ្នកចេញភាគហ៊ុន តាមច្បាប់ស្តីពីការគ្រប់គ្រងមូលបត្ររបស់សហរដ្ឋអាមេរិក ការហាមឃាត់ពីការជួញដូររបស់អ្នកខាងក្នុងដែលពាក់ព័ន្ធនឹងភាគហ៊ុនរបស់ក្រុមហ៊ុន Crown អនុវត្តចំពោះនិយោជិត ភ្នាក់ងារ អ្នកគ្រប់គ្រង មន្ត្រី និងនាយកទាំងអស់របស់ក្រុមហ៊ុន Crown ទូទាំងពិភពលោក។

គោលការណ៍ស្តីពីការជួញដូរក្រៅប្រទេស

<u>ទណ្ឌកម្ម</u>

ក្រុមហ៊ុន Crown ត្រូវតែគោរពតាមកម្មវិធី និងច្បាប់ស្តីពីទណ្ឌកម្មសេដ្ឋកិច្ច និងពាណិជ្ជកម្មជាធរមាន។ ឧទាហរណ៍ ការិយាល័យគ្រប់គ្រងទ្រព្យសកម្មបរទេសរបស់សហរដ្ឋអាមេរិកអនុវត្តការរឹតបន្តឹងរបស់សហរដ្ឋអាមេរិកលើការធ្វើអាជីវកម្មជាមួយប្រទេស អង្គភាព និងបុគ្គលមួយចំនួន។

<u>ការប្រឆាំងនឹងការធ្វើពាហិកា</u>

ក្រុមហ៊ុន Crown ត្រូវតែអនុលោមតាមច្បាប់ស្តីពីការប្រឆាំងនឹងការធ្វើពាហិកាដែលមានជាធរមាន។ ឧទាហរណ៍ ច្បាប់ស្តីពីការប្រឆាំងការធ្វើពាហិការបស់សហរដ្ឋអាមេរិកជាទូទៅហាមឃាត់ក្រុមហ៊ុនរបស់សហរដ្ឋអាមេរិក និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួនទូទាំងពិភពលោកមិនឱ្យសហការជាមួយនឹងការធ្វើពាហិកាអន្តរជាតិដែលរដ្ឋាភិបាលសហរដ្ឋអាមេរិកមិនដាក់ទណ្ឌកម្ម។ ការធ្វើពាហិកាកើតឡើងនៅពេលមនុស្សមួយនាក់ ឬក្រុមមនុស្សបដិសេធមិនធ្វើអាជីវកម្មជាមួយនឹងមនុស្ស ឬប្រទេសមួយចំនួនផ្សេងទៀត។

<u>ច្បាប់ស្តីពីការគ្រប់គ្រងការនាំចេញ</u>

ក្រុមហ៊ុន Crown ត្រូវតែអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងការនាំចេញថ្នាក់ជាតិ និងពហុជាតិដែលមានជាធរមាន។ ឧទាហរណ៍ ច្បាប់ស្តីពីការគ្រប់គ្រងការនាំចេញរបស់សហរដ្ឋអាមេរិក អនុវត្តចំពោះការនាំចេញ និងការនាំចេញបន្តនូវទំនិញ និងបច្ចេកវិទ្យារបស់សហរដ្ឋអាមេរិក។ ក្នុងកាល:ទេស: មួយចំនួន ច្បាប់ទាំងនេះហាមឃាត់ក្រុមហ៊ុន និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់
ក្រុមហ៊ុនសហរដ្ឋអាមេរិក រួមមានក្រុមហ៊ុនដែលមានទីតាំងនៅក្រៅសហរដ្ឋអាមេរិក មិនឱ្យជួញដូរដោយផ្ទាល់ ឬដោយប្រយោលជាមួយនឹងប្រទេសមួយចំនួនដែលពាក់ព័ន្ធនឹងប្រតិបត្តិការមួយចំនួន។

រាល់និយោជិតរបស់ក្រុមហ៊ុន Crown ដែលមានសំណួរពាក់ព័ន្ធនឹងការអនុវត្តនូវច្បាប់ស្តីពីទណ្ឌកម្មការប្រឆាំងនឹងការធ្វើពាហិកា ឬការគ្រប់គ្រងការនាំចេញ គួរតែពិគ្រោះយោបល់ជាមួយនឹងនាយកដ្ឋានច្បាប់នៅក្នុងផ្នែករបស់ខ្លួន។

គោលការណ៍ប្រឆាំងនឹងអំពើពុករលួយ

និយោជិត មន្ត្រី នាយក ឬភាគីទីបីឯករាជ្យរបស់ក្រុមហ៊ុន Crown ដែលធ្វើសកម្មភាពតាងនាមឱ្យក្រុមហ៊ុនមិនអាចបង់ប្រាក់ ផ្តល់ជូន ឬសន្យាថានឹងបង់ប្រាក់ ឬអនុញ្ញាតឱ្យធ្វើការទូទាត់ទៅឱ្យភាគី សាធារណៈ ឬឯកជនណាមួយនៅក្នុងប្រទេសណាមួយ ដើម្បីទទួលបានអត្ថប្រយោជន៍មិនសមរម្យសម្រាប់ក្រុមហ៊ុនឡើយ។ ពួកគេក៏មិនអាចទទួលយក ឬស្នើសុំការទូទាត់បែបនេះបានដែរ។ “ការទូទាត់” រួមបញ្ចូលទាំងសំណូក ឬការសូកប៉ាន់ ក៏ដូចជាការប្រគល់នូវអ្វីដែលមានតម្លៃមិនថាជារបស់ ឬសាច់ប្រាក់ (ដូចជា អំណោយ ការកម្សាន្ត ការចំណាយការធ្វើដំណើរ ការបរិច្ចាគសប្បុរសធម៌ វិភាគទានឧយោបាយ ការជួលបុគ្គល ឬសាច់ញាតិ)។

<u>សូមមើលវិញ្ញាបនបត្រស្តីពីការប្រឆាំងនឹងអំពើពុករលួយ និងការប្រឆាំងនឹងការសម្អាតប្រាក់</u>

<u>អំណោយ ការបរិច្ចាគ ការកម្សាន្ត និងការអនុគ្រោះ</u>

ក្រុមហ៊ុន Crown ទទួលស្គាល់ថា ការផ្លាស់ប្តូរម្តងម្កាលនូវការគួរសមផ្នែកអាជីវកម្ម ដូចជាអំណោយតិចតួច អាហារ និងការកម្សាន្ត (រាប់បញ្ចូលទាំងការអញ្ជើញឱ្យចូលរួមព្រឹត្តិការណ៍កីឡា ឬពិធីជប់លៀងថ្លៃឈប់សម្រាក) គឺជាទម្លាប់ធម្មតាមួយដែលមានគោលបំណងបង្កើតសុជ្ឈន្ទ: និងបង្កើតទំនុកចិត្តលើទំនាក់ទំនង។ ដូច្នេះ គោលការណ៍នេះមិនមានចេតនារារាំងការផ្តល់ ឬការទទួលយកនូវការគួរសមទូទៅនោះទេ ពីព្រោះថាតម្លៃនៃការដឹងគុណគឺស្ថិតលើពាក់ព័ន្ធនឹងកាល:ទេស: ដែលតម្លៃនៃការដឹងគុណត្រូវបានផ្តល់ជូន និងទទួលយក ឬស្របតាមការអនុវត្តអាជីវកម្មដែលបានទទួលយកជាទូទៅរបស់ប្រទេស និងឧស្សាហកម្ម ហើយមិនមានបំណងជះឥទ្ធិពលដល់ការសម្រេចចិត្តផ្នែកអាជីវកម្មរបស់បុគ្គលដែលពាក់ព័ន្ធនោះទេ។ និយោជិតគួរតែជៀសវាងការប្រព្រឹត្តណាមួយដែលសូម្បីតែបង្កើតឱ្យមានអារម្មណ៍ថាមិនត្រឹមត្រូវ។ និយោជិតដែលត្រូវបានផ្តល់ជូន ឬទទួលអំណោយដ៏លក្ខណ:ដែលផ្គុំនឹងគោលការណ៍នេះគួរតែបដិសេធ ឬប្រគល់អំណោយនោះទៅវិញដោយលក្ខណ:គួរសម។

និយោជិតមិនអាចផ្តល់ឱ្យ ឬទទួលយកអ្វីដែលមានតម្លៃធំជាងតម្លៃសួចស្តើងទៅឱ្យ ឬពីអតិថិជន អ្នកផ្គត់ផ្គង់ អ្នកលក់ មន្ត្រីសាធារណ: ឬគណបក្សនយោបាយ ឬបុគ្គលផ្សេងទៀតដែលមានមុខតំណែងប្រហាក់ប្រហែលគ្នានាពេលបច្ចុប្បន្ន ឬអនាគត។ ការផ្តល់ ឬការទទួលយកអំណោយជាសាច់ប្រាក់ (រួមទាំងសាច់ប្រាក់សមមូល ដូចជាភាគហ៊ុន ឬបណ្ណភាគហ៊ុន) ប្រាក់កម្ចី ផ្តល់ខ្លួន ការបញ្ចុះតម្លៃ ឬអំណោយ ឬការអនុគ្រោះណាមួយផ្សេងទៀតដែលអាចត្រូវបានចាត់ទុកថាជាសំណូក ឬការសូកប៉ាន់ ឬការទូទាត់ខុសច្បាប់ ឬអសីលធម៌ផ្សេងទៀត ត្រូវបានហាមឃាត់យ៉ាងតឹងរ៉ឹងដោយមិនគិតពីតម្លៃឡើយ។ លើសពីនេះ និយោជិតរបស់ក្រុមហ៊ុន Crown មិនអាចស្នើសុំអំណោយ ការដឹងគុណ ឬការអញ្ជើញទទួលទានអាហារ ឬការកម្សាន្តពីអ្នកណាម្នាក់ដែលក្រុមហ៊ុន Crown ធ្វើអាជីវកម្ម ឬកំពុងចរចាធ្វើអាជីវកម្មឡើយ។ ទោះក្នុងកាល:ទេស:ណាក៏ដោយ មូលនិធិសាជីវកម្មរបស់ក្រុមហ៊ុន Crown មិនអាចត្រូវបានប្រើប្រាស់ដោយខុសច្បាប់សម្រាប់ការចូលរួមចំណែកនយោបាយប្រភេទណាមួយបានឡើយ។

គោលការណ៍នេះមានគោលបំណងអនុវត្តចំពោះនិយោជិត មន្ត្រី និងនាយកទាំងអស់របស់ក្រុមហ៊ុន Crown និងសមាជិកគ្រួសារជិតស្និទ្ធរបស់ពួកគេក៏ដូចជាភាគីទីបីឯករាជ្យក្នុងនាមក្រុមហ៊ុនដែល រួមមានភ្នាក់ងារភាគីទីបី អ្នកចែកចាយ អ្នកពិគ្រោះយោបល់ អ្នកម៉ៅការ និងអ្នកបញ្ចុះបញ្ចូល និងដៃគូរិនិយោគរួមទុនរបស់ក្រុមហ៊ុន Crown។ សូមមើលសៀវភៅណែនាំស្តីពីគោលការណ៍ប្រឆាំងនឹងអំពើពុករលួយរបស់ក្រុមហ៊ុន Crown ដើម្បីទទួលបានព័ត៌មានលម្អិតបន្ថែម និងឧទាហរណ៍នានាអំពីបញ្ហាដែលអាចកើតមាន។ ប្រសិនបើបុគ្គល ដែលត្រូវបានរាប់បញ្ចូល មានសំណួរណាមួយទាក់ទងនឹងការអនុវត្តគោលការណ៍នេះ បុគ្គលនោះគួរតែបង្ហាញពីកាល:ទេស:ដែលពាក់ព័ន្ធ និងស្វែងរកការយល់ព្រមពីប្រធានផ្នែកពាក់ព័ន្ធ ឬពីនាយកដ្ឋានច្បាប់របស់ក្រុមហ៊ុន Crown។

គោលការណ៍ច្បាប់ស្តីពីការប្រកួតប្រជែង

ក្រុមហ៊ុន Crown ប្រកួតប្រជែងដោយស្មោះត្រង់ យុត្តិធម៌ និងឯករាជ្យសម្រាប់អាជីវកម្ម តាមលក្ខណ:ប្រកបដោយក្រមសីលធម៌នៅគ្រប់ផ្នែកនៃទីផ្សារទាំងអស់សម្រាប់ផលិតផលរបស់ក្រុមហ៊ុន Crown។ ច្បាប់ស្តីពីការប្រកួតប្រជែងរបស់បណ្តាប្រទេសដែលក្រុមហ៊ុន Crown ធ្វើអាជីវកម្ម គឺជាគ្រឹះនៃសហគ្រាសប្រកួតប្រជែងដោយសេរី។

ក្រុមហ៊ុន Crown តម្រូវឱ្យនិយោជិតទាំងអស់ប្រតិបត្តិតាមយ៉ាងពេញលេញនូវច្បាប់ស្តីពីការប្រកួតប្រជែងរបស់បណ្តាប្រទេសដែលក្រុមហ៊ុន Crown ធ្វើអាជីវកម្ម។ វាជារឿងខុសច្បាប់នៅក្នុងសហរដ្ឋអាមេរិក និងប្រទេសជាច្រើនទៀតដែលក្រុមហ៊ុន Crown ធ្វើអាជីវកម្មដើម្បីចុះកិច្ចព្រមព្រៀង ការយោគយល់ ឬការពិភាក្សាជាមួយដៃគូប្រកួតប្រជែងរបស់យើងទាក់ទងនឹង: តម្លៃ ឬការបញ្ចុះតម្លៃ លក្ខខណ្ឌនៃការលក់ រួមមានចិរវេលាឥណទាន ប្រាក់ចំណេញប្រាក់ចំណេញដុល ឬការចំណាយ ចំណែកទីផ្សារ ការអនុវត្ត ឬបណ្តាញចែកចាយ ការដេញថ្លៃ ឬចេតនាដេញថ្លៃ ពង្រីកសមត្ថភាព ឬចូលទីផ្សារថ្មី ការជ្រើសរើស ការចាត់ថ្នាក់ ការបដិសេធ ឬការបញ្ចប់អតិថិជន ឬប្រភេទអតិថិជន ដែនដីនៃការលក់ ឬទីផ្សារ ការផ្លាស់ប្តូរព័ត៌មានប្រកួតប្រជែង

ឬបញ្ហាផ្សេងៗណាមួយដែលមិនស៊ីចង្វាក់នឹងសេរីភាពពេញលេញនៃសកម្មភាព និងឯករាជ្យភាពរបស់ក្រុមហ៊ុនក្នុងការធ្វើអាជីវកម្មរបស់ខ្លួនឡើយ។ ក្រុមហ៊ុន Crown មិនចូលទៅក្នុងកិច្ចសន្យាណាមួយជាមួយអតិថិជន ឬអ្នកផ្គត់ផ្គង់ដែលរឹតត្បឹតការប្រកួតប្រជែងដោយសេរី និងបើកចំហដោយមិនសមហេតុផល ឬខុសច្បាប់ និងពិគ្រោះយោបល់ជាប្រចាំជាមួយអ្នកជំនាញច្បាប់ប្រកួតប្រជែងដើម្បីធានាបាននូវភាពស្របច្បាប់នៃទង្វើដែលបានស្នើឡើង។

ប្រធានផ្នែក និងអនុប្រធានផ្នែកលក់ និងនាយកដ្ឋានច្បាប់ចែករំលែកការប្តេជ្ញាចិត្តរបស់ក្រុមហ៊ុន Crown ក្នុងការប្រតិបត្តិតាមច្បាប់ស្តីពីការប្រកួតប្រជែង។ សូមពិគ្រោះជាមួយពួកគេមុននឹងផ្តល់ការបញ្ចុះតម្លៃផ្សេងៗ ប្រាក់ត្រលប់មកវិញ ប្រាក់ឧបត្ថម្ភ ឬការកែប្រែតម្លៃផ្សេងៗទៀត ឬលក្ខខណ្ឌផ្សេងនៃការលក់ជូនអតិថិជនផ្សេងៗគ្នាសម្រាប់ផលិតផលតែមួយ ឬប្រសិនបើអ្នកមានសំណួរឬកង្វល់ណាមួយ ហើយរាល់ពេលដែលអ្នកត្រូវការជំនួយក្នុងការស្វែងយល់ ឬប្រតិបត្តិតាមគោលការណ៍នេះ។

គោលការណ៍ស្តីពីបរិស្ថាន សុខភាព និងសុវត្ថិភាព

ក្រុមហ៊ុន Crown ទទួលស្គាល់ថា ការការពារសុខភាពមនុស្ស និងបរិស្ថានគឺជាការធ្វើអាជីវកម្មដ៏ត្រឹមត្រូវមួយដែលអភិរក្សធនធាន និងការពារនិយោជិត អតិថិជន សាធារណជន និងបរិស្ថានទូទៅ។ នីយោជិតរបស់ក្រុមហ៊ុន Crown គ្រប់រូបចែករំលែកការទទួលខុសត្រូវនេះក្នុងការធានាឱ្យបានជោគជ័យរយៈពេលវែងសម្រាប់ក្រុមហ៊ុន Crown។

ដើម្បីអនុវត្តនូវគោលការណ៍នេះ ក្រុមហ៊ុន Crown និងនិយោជិតរបស់ខ្លួនត្រូវតែ៖

- ប្តេជ្ញាចិត្តចំពោះភាពជាអ្នកដឹកនាំដោយប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុន Crown ស្របតាមលក្ខខណ្ឌតម្រូវរបស់បទប្បញ្ញត្តិទាំងអស់ និងបទដ្ឋាន និងគោលការណ៍ស្តីពីបរិស្ថាន សុខភាព និងសុវត្ថិភាពរបស់ក្រុមហ៊ុន Crown។

- ពង្រឹងវប្បធម៌បុរេសកម្មផ្នែកបរិស្ថាន សុខភាព និងសុវត្ថិភាពរបស់ក្រុមហ៊ុន Crown ដោយបង្កើនការយល់ដឹង និងចំណេះដឹងក្នុងចំណោមនិយោជិតគ្រប់លំដាប់ថ្នាក់ និងប្តេជ្ញាចំពោះការការពារ និងសុខុមាលភាពរបស់និយោជិតគ្រប់រូប។

- លើកកម្ពស់ការការពារការបំពុលដោយផ្តោតលើការកាត់បន្ថយប្រភព និងការអភិរក្សធនធាននិងរួមបញ្ចូលការពិចារណាពីបរិស្ថាន សុខភាព និងសុវត្ថិភាពក្នុងចំណោមលក្ខណៈវិនិច្ឆ័យដែលគម្រោង ផលិតផល ដំណើរការ និងការទិញត្រូវបានវាយតម្លៃ។

- តម្រូវឱ្យនិយោជិតគ្រប់រូបទទួលខុសត្រូវចំពោះការងារ និងសន្តិសុខពាក់ព័ន្ធនឹងបរិស្ថាន សុខភាពនិងសុវត្ថិភាពរបស់ខ្លួន និយោជិតជាមិត្ត និងក្រុមហ៊ុន។

- វាយតម្លៃការងារ និងកម្មវិធីពាក់ព័ន្ធនឹងបរិស្ថាន សុខភាពនិងសុវត្ថិភាព និងប្តេជ្ញាកែលម្អជាបន្តបន្ទាប់ទៅគោលដៅកំណត់ដែលគ្មានគ្រោះថ្នាក់ និងគ្មានផលប៉ះពាល់។

គោលការណ៍ស្តីពីអាថ៌កំបាំងពាណិជ្ជកម្ម និងព័ត៌មានសម្ងាត់

ព័ត៌មានអាជីវកម្ម

និយោជិតរបស់ក្រុមហ៊ុន Crown ដោះស្រាយរៀងរាល់ថ្ងៃជាមួយព័ត៌មានអំពីក្រុមហ៊ុន និងអាជីវកម្មរបស់ក្រុមហ៊ុន។ ព័ត៌មាននេះរួមមានផែនការអាជីវកម្ម ដំណើរការផលិតកម្ម និងបច្ចេកវិទ្យា ការធ្វើទីផ្សារ និងព័ត៌មានតម្លៃ បញ្ជីអតិថិជន និងផែនការសម្រាប់អាជីវកម្ម និងការបណ្តាក់ទុនថ្មីៗ។ អាជីវកម្មរបស់ក្រុមហ៊ុន Crown អាចនឹងត្រូវខូចខាត ប្រសិនបើព័ត៌មាននេះត្រូវបានបង្ហាញដល់ដៃគូប្រកួតប្រជែង ឬទៅអ្នកណាមាក់ផ្សេងទៀតនៅក្រៅក្រុមហ៊ុននោះ។

និយោជិតនីមួក់ៗរបស់ក្រុមហ៊ុន Crown ត្រូវសន្មតថា រាល់ព័ត៌មានទាំងអស់នោះគឺជាការសម្ងាត់ (លើកលែងតែកាល:ទេស:ដែលក្រុមហ៊ុន Crown បានបង្ហាញព័ត៌មាននៅក្នុងរបាយការណ៍ដែលបានផ្សព្វផ្សាយ ឬនៅពេលដែលនិយោជិតអាចផ្តៀងផ្តាត់ថាព័ត៌មាននោះត្រូវបានដឹងជាសាធារណ:ឬអត់)។ ដូចគ្នានេះដែរ
និយោជិតនីម្នាក់ៗរបស់ក្រុមហ៊ុន Crown គួរសន្មតថារាល់ព័ត៌មានដែលបានបង្ហាញដល់ក្រុមហ៊ុន Crown ដោយអតិថិជន និងអ្នកផ្គត់ផ្គង់របស់ខ្លួនគឺជាការសម្ងាត់ (លើកលែងតែកាល:ទេស:ដែលអតិថិជន ឬអ្នកផ្គត់ផ្គង់បានយល់ស្របច្បាស់លាស់ចំពោះការបង្ហាញព័ត៌មានរបស់ខ្លួន ឬនិយោជិតអាចផ្តៀងផ្តាត់ថាព័ត៌មានត្រូវបានដឹងជាសាធារណ:ឬអត់)។ និយោជិតនីមួយៗរបស់ក្រុមហ៊ុន Crown មានកាតព្វកិច្ចក្នុងអំឡុងពេល និងក្រោយពេលបំពេញការងាររបស់ខ្លួនក្នុងការរក្សាព័ត៌មានសម្ងាត់ទាំងអស់ដោយភាពជឿជាក់បដិសេធមិនបង្ហាញ
ព័ត៌មានបែបនេះដល់មនុស្សណាម្នាក់នៅខាងក្រៅក្រុមហ៊ុនដោយគ្មានការយល់ព្រមពីក្រុមហ៊ុនជាមុន និងបដិសេធមិនប្រើប្រាស់ព័ត៌មានបែបនេះសម្រាប់គោលបំណងផ្សេងទៀតក្រៅពីការអនុវត្តភារកិច្ចរបស់ខ្លួនចំពោះក្រុមហ៊ុន លើកលែងតែនៅពេលដែលការបង្ហាញព័ត៌មាននេះតម្រូវដោយច្បាប់ជាធរមាន។ គោលនយោបាយនេះឬកិច្ចព្រមព្រៀងផ្សេងទៀតជាមួយ Crown ទាក់ទងនឹងបញ្ហាការសម្ងាត់ នឹងមិនធ្វើការរឹតត្បិត ឬរារាំងនិយោជិត Crown ពីការបង្កើតការប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយភ្នាក់ងារឬអាជ្ញាធររដ្ឋាភិបាលឆ្លើយតបទៅនឹងសំណួរណាមួយ ផ្តល់ព័ត៌មានឬរាយការណ៍អំពីការរំលោភបំពានទៅភ្នាក់ងារឬអាជ្ញាធររដ្ឋាភិបាលទាំងនោះ ឬពីការលាតត្រដាងព័ត៌មានផ្សេងទៀតដែលត្រូវបានការពារក្រោមបទប្បញ្ញត្តិស្តីអំពីអ្នករាយការណ៍ព័ត៌មានដោយសម្ងាត់ក្នុងច្បាប់ជាធរមាននោះទេ។
និយោជិតរបស់ក្រុមហ៊ុន Crown មិនត្រូវការការអនុញ្ញាតជាមុនពីក្រុមហ៊ុនដើម្បីរាយការណ៍ឬធ្វើការលាតត្រដាងបែបនេះទេ ហើយនិយោជិតមិនត្រូវបានតម្រូវឱ្យជូនដំណឹងដល់ក្រុមហ៊ុនអំពីរបាយការណ៍ឬការលាតត្រដាងបែបនេះទេ។

ព័ត៌មានផ្ទាល់ខ្លួន

ទិន្នន័យផ្ទាល់ខ្លួនត្រូវប្រមូល និងរក្សាទុកដោយសម្ងាត់ដែលជានាថាទិន្នន័យទាំងនោះអាចប្រើប្រាស់បានលុះត្រាតែអនុលោមតាមច្បាប់ជាធរមាន និងសម្រាប់តែបុគ្គលទាំងនោះដែលមានអាជីវកម្មស្របច្បាប់ប៉ុណ្ណោះដែលត្រូវការដឹងពីទិន្នន័យទាំងនោះ។

គោលការណ៍ស្តីពីឱកាសការងារស្មើភាពគ្នា ការរើសអើង និងការបៀតបៀន

និយោជិតទាំងអស់មានសិទ្ធិទទួលបានការប្រព្រឹត្តដោយសេចក្តីគោរព និងសេចក្តីថ្លៃថ្នូរ ហើយដូច្នេះដើម្បីធ្វើការក្នុងបរិយាកាសស្អាតការរើសអើងមិនស្របច្បាប់ចំពោះការងារគ្រប់ទម្រង់ទាំងអស
រួមទាំងការបៀតបៀនផ្លូវភេទ និងការបៀតបៀនដោយផ្អែកលើពូជសាសន៍ ពណ៌សម្បុរ ដើមកំណើតជាតិ ពូជពង្សសញ្ជាតិ ជាតិសាសន៍ សាសនា អាយុ ភេទ យេនឌ័រ ទំនោរផ្លូវភេទ អត្តសញ្ញាណយេនឌ័រ ការបញ្ចេញមតិពិការភាពផ្នែករាងកាយ ឬផ្លូវចិត្ត ព័ត៌មានសេនេទិក សេវាកម្មជាឯកសណ្ឋាន ស្ថានភាពយុទ្ធជន ឬលក្ខណៈផ្សេងទៀតដែលការពារដោយច្បាប់ បញ្ញត្តិ ឬបទប្បញ្ញត្តិជាធរមាន។ ដូច្នេះ ក្រុមហ៊ុន Crown មានគោលការណ៍ហាមឃាត់យ៉ាងតឹងរ៉ឹងចំពោះការរើសអើងមិនស្របច្បាប់ រួមទាំងការបៀតបៀនក្នុងទម្រង់ណាមួយមកលើនិយោជិតដោយអ្នកគ្រប់គ្រង មិត្តរួមការងារ អ្នកលក់ ឬអតិថិជនរបស់និយោជិត។
ការប្រព្រឹត្តបែបនេះក៏មិនត្រូវបានអត់ឱនដែរ ហើយគួរតែត្រូវបានរាយការណ៍ភ្លាមៗដូចដែលបានរៀបរាប់នៅក្នុងគោលការណ៍នេះ។ វាក៏ជាគោលការណ៍របស់ក្រុមហ៊ុន Crown ផងដែរក្នុងការមិនរើសអើងចំពោះអ្នកដាក់ពាក្យសុំការងារនៅលើមូលដ្ឋានណាមួយដែលបានរៀបរាប់ពីខាងលើ។

សម្រាប់គោលបំណងនៃគោលការណ៍នេះ ការបៀតបៀនត្រូវបានកំណត់ថាជាការប្រព្រឹត្តដោយពាក្យសម្តី ឬកាយវិការដែលបរិហារ ឬបង្ហាញពីអរិភាព ឬការមិនពេញចិត្តចំពោះបុគ្គលណាម្នាក់សម្រាប់ហេតុផលណាមួយដែលបានរៀបរាប់ពីខាងលើ និង៖

- មានគោលបំណង ឬមានឥទ្ធិពលលើការបង្កើតបរិយាកាសការងារដែលមានលក្ខណៈបំភិតបំភ័យ អរិភាព ឬលក្ខណៈប៉ះពាល់។
- មានគោលបំណង ឬមានឥទ្ធិពលលើការជ្រៀតជ្រែកដោយមិនសមហេតុផលក្នុងការអនុវត្តការងាររបស់បុគ្គល ឬ
- បើប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ឱកាសការងាររបស់បុគ្គល។

ឧទាហរណ៍មួយចំនួននៃការបៀតបៀនបែបនេះគឺ៖ ការប្រើវិសេសសព្វ ការប្រើផ្នត់គំនិតបង្អាប់បង្អូចឬអរិដ្ឋមានការគំរាមកំហែង ការបំភិតបំភ័យឬចូលរួមក្នុងអំពើអរិភាព ដែលទាក់ទងនឹងលក្ខណៈដែលមានការការពារ រឿងកំប្លែងឬការលេងបញ្ឆោតមិនពិត ការបិទនៅលើជញ្ជាំង ផ្ទាំងព្រឹត្តិបត្រឬកន្លែងផ្សេងទៀតនៅក្នុងបរិវេណក្រុមហ៊ុន (ឬចរាចរណ៍នៅកន្លែងធ្វើការតាមរយៈប្រព័ន្ធផ្សព្វផ្សាយណាមួយ) ដោយផ្ទាល់មាត់ ជាលាយលក្ខណ៍អក្សរ ឬក្រាហ្វិកដែលបរិហារឬបង្ហាញពីអរិភាព ឬការស្អប់ខ្ពើមចំពោះបុគ្គល ឬក្រុមដោយសារតែលក្ខណៈដែលមានការការពារ។

គោលការណ៍ស្តីពីការដោះស្រាយដោយយុត្តិធម៌ និងការពិតនៅក្នុងរបាយការណ៍ និងកំណត់ត្រា

និយោជិតរបស់ក្រុមហ៊ុន Crown គួរតែព្យាយាមដោះស្រាយដោយស្មើភាពជាមួយអតិថិជន ក្រុមហ៊ុនផ្គត់ផ្គង់ ដៃគូប្រកួតប្រជែង និងនិយោជិតរបស់ក្រុមហ៊ុន។ និយោជិតរបស់ក្រុមហ៊ុន Crown ត្រូវបានហាមឃាត់មិនឱ្យទាញយកផលប្រយោជន៍ដោយអយុត្តិធម៌ពីនរណាម្នាក់តាមរយៈឧបាយកល ការលាក់បាំង ការបំពានលើព័ត៌មានដែលមានឯកសិទ្ធិ ការបង្ហាញមិនពិតអំពីអង្គហេតុជាសម្ភារៈឯកសារ ឬការអនុវត្តការដោះស្រាយបញ្ហាមិនយុត្តិធម៌ផ្សេងទៀត។

និយោជិតក្រុមហ៊ុន Crown មិនត្រូវបង្កើត រក្សា ឬដាក់បញ្ចូនកំណត់ត្រា របាយការណ៍ ឬសេចក្តីថ្លែងការណ៍ដែលមិនត្រឹមត្រូវ មិនពិត ឬមានលក្ខណៈបំភាន់ដោយចេតនាឡើយ។ និយោជិតក្រុមហ៊ុន Crown ទាំងអស់មានកាតព្វកិច្ចបញ្ជាក់ ដើម្បីជានាថាសេចក្តីថ្លែងការណ៍ ឬការតំណាងណាមួយដែលធ្វើឡើងតាងនាមឱ្យក្រុមហ៊ុន Crown គឺជាការពិត និងត្រឹមត្រូវ។ ទោះបីជាគោលការណ៍នេះអនុវត្តចំពោះទំនាក់ទំនងទាំងអស់ដែលធ្វើឡើងក្នុងនាមរបស់ក្រុមហ៊ុន Crown ក៏ដោយ វាមានសារៈសំខាន់ជាពិសេសទាក់ទងនឹងសេចក្តីថ្លែងការណ៍ លិខិតឬឯកសារណាមួយដែលត្រូវបានបញ្ជូនទៅ ឬអាចពឹងផ្អែកលើទីភ្នាក់ងាររដ្ឋាភិបាលណាមួយ។

ការក្លែងបន្លំកំណត់ត្រា ការដាក់ស្នើ ឬសេចក្តីថ្លែងការណ៍ គឺជាប្រភេទនៃការប្រព្រឹត្ត ដែលទំនងជាអាចបណ្តាលឱ្យមានការបំពានច្បាប់ ក៏ដូចជាការលេចចេញនូវភាពមិនសមរម្យផងដែរ។ បុគ្គលដែលបំពេញ ឬជាអ្នកទទួលខុសត្រូវ ឬជាអ្នកធ្វើសេចក្តីថ្លែងការណ៍ទៅកាន់ភ្នាក់ងាររដ្ឋាភិបាល ឬនិយតកម្ម ត្រូវតែអនុវត្តការយកចិត្តទុកដាក់ ដើម្បីជានាថា កំណត់ត្រា ឬសេចក្តីថ្លែងការណ៍ទាំងនោះមានភាពត្រឹមត្រូវ។ ក្នុងន័យនេះ ការនិយាយការពិត និងទទួលស្គាល់ភាពអវិជ្ជាគឺជាប្រការល្អនៅពេលប្រឈមមុខជាជាងការនិយាយស្មានៗ។ ដូចគ្នានេះដែរ និយោជិតរបស់ក្រុមហ៊ុន Crown គួរតែពិនិត្យមើលអង្គហេតុជានិច្ច ដើម្បីប្រាកដថាព័ត៌មាននេះមានភាពសុក្រឹតជាជាងផ្តល់ព័ត៌មាន ឬរបាយការណ៍ទៅភ្នាក់ងាររដ្ឋាភិបាល ឬនិយតកម្មដោយផ្អែកលើការស្មាន ឬការសន្មត។

គោលការណ៍ស្តីពីរបាយការណ៍ហិរញ្ញវត្ថុ

នាយកប្រតិបត្តិរបស់ក្រុមហ៊ុន Crown Holdings, Inc., ប្រធានផ្នែកហិរញ្ញវត្ថុ, អ្នកត្រួតពិនិត្យ និងសមាជិកទាំងអស់នៃនាយកដ្ឋានហិរញ្ញវត្ថុរបស់ខ្លួន ដែលមានទំនួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុត្រូវ:

- ចូលរួម និងលើកកម្ពស់ការប្រព្រឹត្តស្មោះត្រង់ និងប្រកបដោយសីលធម៌ រួមទាំងការដោះស្រាយបញ្ហាប្រកបដោយក្រមសីលធម៌លើទំនាស់ផលប្រយោជន៍ជាក់ស្តែង ឬអាចមើលឃើញច្បាស់រវាងទំនាក់ទំនងផ្ទាល់ខ្លួន និងទំនាក់ទំនងវិជ្ជាជីវៈ។
- លើកកម្ពស់ការបង្ហាញព័ត៌មានពេញលេញ យុត្តិធម៌ ត្រឹមត្រូវ ទាន់ពេលវេលា និងអាចយល់បាននៅក្នុងរបាយការណ៍ និងឯកសារដែល Crown ដាក់ជូន ឬដាក់បញ្ជូនទៅគណៈកម្មការមូលបត្រសហរដ្ឋអាមេរិក និងនៅក្នុងទំនាក់ទំនងសាធារណៈផ្សេងទៀត
- អនុលោមតាមច្បាប់ វិធាន និងបទប្បញ្ញត្តិដែលមានជាធរមាន
- រាយការណ៍ភ្លាមៗអំពីការបំពានក្រមប្រតិបត្តិ និងក្រមសីលធម៌អាជីវកម្មទៅកាន់ក្រុមប្រឹក្សាទូទៅ ឬទំនាក់ទំនងណាមួយដែលមានរាយបញ្ជីនៅទីនេះ និង
- ទទួលខុសត្រូវចំពោះការប្រកាន់ខ្ជាប់តាមចំណុចខាងលើ។

កាតព្វកិច្ចរបស់និយោជិក

និយោជិតក្រុមហ៊ុន Crown ទាំងអស់ ចាប់ពីគណៈគ្រប់គ្រងប្រតិបត្តិ រហូតដល់គណៈគ្រប់គ្រងរោងចក្រ រហូតដល់បុគ្គលិកពេញម៉ោង និងក្រៅម៉ោង តម្រូវឱ្យអនុវត្តតាមគោលការណ៍ដែលមានចែងក្នុងក្រមនេះ។ លើសពីនេះ និយោជិតក្រុមហ៊ុន Crown ទាំងអស់ត្រូវតែគោរពច្បាប់ វិធាន និងបទប្បញ្ញត្តិដែលមានជាធរមានគ្រប់ពេលវេលា មិនថាការអនុវត្តធ្វើឡើងនៅក្នុងស្រុក ឬឧស្សាហកម្មស្ថិតនៅក្នុងតំបន់ណាមួយឡើយ។ ការខកខានមិនបានអនុវត្តតាមគោលការណ៍ទាំងនេះអាចបណ្តាលឱ្យមានការដាក់វិន័យ រហូតដល់ និងរួមទាំងការបណ្តេញចេញផងដែរ។

និយោជិតក្រុមហ៊ុន Crown ណាម្នាក់ដែលមានសំណួរអំពីថាតើសកម្មភាពជាក់លាក់ណាមួយ ដែលគាត់កំពុងធ្លឹងថ្លែង ឬស្ថានភាពដែលគាត់ជាប់ពាក់ព័ន្ធ អាចមិនស្របនឹងគោលការណ៍ក្រុមហ៊ុន ឬអាចមិនសមរម្យ សម្រាប់ហេតុផលផ្សេងទៀត គួរតែលើកអំពីសំណួរជាមួយប្រធានផ្នែកផ្ទាល់របស់គាត់ អ្នកគ្រប់គ្រងរោងចក្រ ឬការិយាល័យអនុលោមភាព ហើយដោះស្រាយបញ្ហានេះមុនពេលធ្វើសកម្មភាព ឬអនុញ្ញាតឱ្យស្ថានភាពនោះបន្ត។

នីតិវិធីស្តីពីអនុលោមភាព និងការរាយការណ៍

និយោជិតផ្នែកគ្រប់គ្រងមួយចំនួននឹងត្រូវបានទាមទារជាទៀងទាត់ ឱ្យដាក់បញ្ជូនការធ្វើងផ្ទាត់ដែលមានហត្ថលេខាចំពោះប្រសិទ្ធភាព ដែលគាត់ធ្លាប់ស្គាល់ជាមួយនឹងគោលការណ៍នៃក្រមសីលធម៌ និងក្រមប្រតិបត្តិនៃការប្រកបអាជីវកម្មរបស់ក្រុមហ៊ុន Crown ហើយបានអង្កេតមើលពួកគេ និងមិនដឹងថាមានការបំពានលើគោលការណ៍ណាមួយឡើយ។
និយោជិតណាដែលទទួលដឹងអំពីការបំពានណាមួយនៃក្រមនេះ
ត្រូវរាយការណ៍ការបំពាននេះភ្លាមៗទៅកាន់ប្រធានផ្នែក អ្នកគ្រប់គ្រងរោងចក្រ
ឬទៅកាន់ការិយាល័យអនុលោមភាព។

និយោជិតណាដែលរាយការណ៍អំពីការបំពាន នឹងត្រូវបានប្រព្រឹត្តដាក់ដោយសេចក្តីថ្លៃថ្នូរ និងការគោរព ហើយនឹងមិនទទួលរងនូវទម្រង់ណាមួយនៃការដាក់វិន័យ ឬការសងសឹកចំពោះរបាយការណ៍ដែលធ្វើឡើងដោយស្មោះត្រង់នោះទេ។ និយោជិតណាម្នាក់ដែលជឿថាគាត់ត្រូវបានប្រព្រឹត្តដាលដោយអយុត្តិធម៌ដោយសារតែការរាយការណ៍បែបនេះ គួរតែរាយការណ៍រឿងនេះទៅការិយាល័យអនុលោមភាពរបស់សាជីវកម្ម ឬផ្នែក។ បុគ្គលណាម្នាក់ដែលត្រូវបានរកឃើញថាបានសងសឹក
ឬដាក់ទណ្ឌកម្មនិយោជិតម្នាក់ទៀតដែលមានភាពស្មោះត្រង់ដោយ
បានរាយការណ៍ពីការបំពាននឹងត្រូវទទួលរងនូវការដាក់វិន័យ រហូតដល់ និងរួមទាំងការបណ្តេញចេញផងដែរ។

<u>មន្ត្រីអនុលោមភាព</u>

ក្រុមហ៊ុន Crown បានតែងតាំងមន្ត្រីអនុលោមភាពដូចខាងក្រោម៖

<u>ផ្នែកសាជីវកម្ម និងអាមេរិក</u>

- Adam Dickstein
  អនុប្រធានជាន់ខ្ពស់, ក្រុមប្រឹក្សាទូទៅ និងលេខាធិការសាជីវកម្ម

- Carrie Kehner
  ជំនួយក្រុមប្រឹក្សាទូទៅ

<u>ផ្នែកនៅអឺរ៉ុប</u>

- លោក Jean-Francois Lelouch
  ប្រធានផ្នែកច្បាប់

<u>ផ្នែកនៅអាស៊ីប៉ាស៊ីហ្វិក</u>

- លោក Ee Ping Han
  នាយកផ្នែកច្បាប់

ការិយាល័យអនុលោមភាពមានទំនួលខុសត្រូវលើគ្រប់ទិដ្ឋភាពនៃការអនុលោមតាមច្បាប់ សម្រាប់ការបង្កើត និងកែសម្រួលគោលការណ៍ ដែលមានចែងក្នុងសៀវភៅណែនាំនេះ និងសម្រាប់ការអនុវត្តនីតិវិធីដែលបានរៀបចំឡើងដើម្បីសម្រេចបាននូវគោលការណ៍ទាំងនេះ។

<u>របៀបរាយការណ៍អំពីការបំពាន</u>

និយោជិតទាំងអស់របស់ក្រុមហ៊ុន Crown ត្រូវតែរាយការណ៍ភ្លាមៗអំពីការបំពានលើគោលការណ៍ និងនីតិវិធីដែលមានចែងក្នុងសៀវភៅណែនាំនេះ។ និយោជិតរបស់ក្រុមហ៊ុន Crown ណាដែលមានសេចក្តីស្មោះត្រង់រាយការណ៍ពីការបំពានលើគោលការណ៍ ឬនីតិវិធីទាំងនេះ អាចនឹងមិនត្រូវបានទទួលទណ្ឌកម្ម ឬទទួលរងការសងសឹកក្នុងទម្រង់ណាមួយឡើយ។

និយោជិតគ្រប់រូបដែលដឹងពីការបំពានគោលការណ៍ ឬនីតិវិធីអនុលោមតាមច្បាប់ មានវិធីបីយ៉ាងក្នុងការរាយការណ៍អំពីវា៖ (1) ទៅកាន់ប្រធានផ្ទាល់របស់គាត់ (2) ទៅអ្នកគ្រប់គ្រងរោងចក្រ ឬសមមូល ឬ (3) ទៅការិយាល័យអនុលោមភាព។

និយោជិតគ្រប់រូបគួរតែរាយការណ៍ពីការបំពានទៅអ្នកប្រធានផ្ទាល់របស់ខ្លួនជាមុនសិន។
ប្រសិនបើនិយោជិតណាម្នាក់មានអារម្មណ៍ស្ទាក់ស្ទើរតាម
មធ្យោបាយណាមួយចំពោះការរាយការណ៍អំពីការបំពានបែបនេះទៅអ្នកប្រធានផ្ទាល់របស់គាត់ (ឧទាហរណ៍ ប្រសិនបើប្រធានផ្ទាល់មានការពាក់ព័ន្ធផ្ទាល់នឹងការបំពាន)
និយោជិតអាចរាយការណ៍អំពីការបំពាននេះទៅអ្នកគ្រប់គ្រងរោងចក្រ ឬទៅការិយាល័យអនុលោមភាព។ ក្នុងករណីណាក៏ដោយ និយោជិតដែលធ្វើការរាយការណ៍ដោយស្មោះត្រង់ អាចមិនត្រូវបានផ្តន្ទាទោស ឬទទួលរងការសងសឹកចំពោះការរាយការណ៍នោះទេ។

ដើម្បីរាយការណ៍ពីការបំពានដែលមានការសង្ស័យទៅការិយាល័យអនុលោមភាពរបស់ក្រុមហ៊ុន Crown, និយោជិតអាចសរសេរ ឬហៅទូរសព្ទទៅមន្ត្រីអនុលោមភាពដូចខាងក្រោម៖

- Adam Dickstein
  Crown Holdings, Inc.
  770 Township Line Road Yardley, PA
  19067
  800-523-3644 Ext. 5576
  adam.dickstein@crowncork.com

- Carrie Kehner
  Crown Holdings, Inc.
  770 Township Line Road Yardley, PA
  19067
  800-523-3644 Ext. 5224
  carrie.kehner@crowncork.com

- Jean-Francois Lelouch
  CROWN Bevcan EMEA
  Stories – 1 rue Touzet-Gaillard
  93400 Saint-Ouen France
  +33 (1) 49 18 42 15
  jean-francois.lelouch@eur.crowncork.com

- Ee Ping Han
  CROWN Asia Pacific Holdings Pte. Ltd. 1
  HarbourFront Place #03-01 HarbourFront, Tower One
  Singapore 098633
  +65 6423 9798
  ee-ping.han@crowncork.com.sg

លើសពីនេះ រាល់ការតវ៉ាទាក់ទងនឹងគណនេយ្យ ការគ្រប់គ្រងផ្ទៃក្នុង ឬបញ្ហាសវនកម្ម គួរតែត្រូវបានទាក់ទងទៅការិយាល័យអនុលោមភាពរបស់ក្រុមហ៊ុន Crown តាមអាសយដ្ឋាន ឬលេខទូរសព្ទដែលបានរាយពីខាងលើ។

រាល់ការតវ៉ាបែបនេះអាចដាក់បញ្ជូនដោយសម្ងាត់ និងអនាមិក។

អ្នកក៏អាចរាយការណ៍ពីការបំពានណាមួយតាមរយៈខ្សែទូរសព្ទផ្ទៃកក្រមសីលធម៌អាជីវកម្មរបស់ Crown (“CBE Line”) ដែលត្រូវបានគ្រប់គ្រងដោយអ្នកផ្តល់សេវាភាគីទីបីឯករាជ្យគឺ Mitratech។ យោងទៅតាមច្បាប់ដែលមានជាធរមាន របាយការណ៍ដែលធ្វើឡើងតាមរយៈ CBE Line នឹងនៅតែមានភាពជាអនាមិកតាមការស្នើសុំ។ ដើម្បីចូលប្រើខ្សែទូរសព្ទ CBE សូមមើល https://report.syntrio.com/crowncork។